កម្មវិធីសុខភាពកម្មកររោងចក្រ



Description : នៅក្នុងប្រទេសកម្ពុជា គ្រឹះស្ថានផ្តល់សេវាសុខភាពគ្រប់ជ្រុងជ្រោយនិងមានគុណភាពសម្រាប់ក្រុមស្ត្រីងាយរង គ្រោះ ឬស្ថិតក្នុងស្ថានភាពលំបាកដូចជា---កម្មកររោងចក្រ នៅមានចំនួនកំណត់នៅឡើយ។ ក្រសួងសុខាភិបាល បានដាក់ឲ្យដំណើរការនូវគ្លីនិកសុខភាពគ្រួសារដែលផ្តោតលើការផ្តល់សេវាសម្រាប់ក្រុមស្ត្រីធ្វើការនៅសេវា កម្សាន្ត និងយកចិត្តទុកដាក់ជាសំខាន់ទៅលើសេវា ជំងឺកាមរោគ និងសេវាធ្វើតេស្តឈាមរកមេរោគអេដស៍ ប៉ុណ្ណោះ។

## គោលបំណង

កម្មវិធីនេះមានគោលបំណងបំពេញតម្រូវការសុខភាពរបស់កម្មកររោងចក្រ តាមរយៈការផ្តល់សេវារួមបញ្ចូលគ្នា រវាងសេវាសុខភាពផ្លូវភេទ និងបន្តពូជ ជាមួយនឹងសេវាទាក់ទងនឹងមេរោគអេដស៍ សម្រាប់កម្មកររោងចក្រ នៅគ្លីនិករ៉ាក់។ លើសពីនេះទៅទៀត អង្គការរ៉ាក់មានគោលបំណងកសាងសមត្ថភាពបុគ្គលិកពេទ្យរោងចក្រ ក្នុងការផ្តល់សេវាសុខភាពផ្លូវភេទ និងសុខភាពបន្តពូជសំខាន់ៗមួយចំនួន នៅតាមរោងចក្ររបស់ពួកគេ។

## សកម្មភាព

ជាច្រើនឆ្នាំកន្លងមក អង្គការរ៉ាក់ បានបង្កើតទំនាក់ទំនងការងារល្អប្រសើរជាមួយនឹងថ្នាក់ដឹកនាំក៏ដូចជាបុគ្គលិក ក្នុងរោងចក្រចំនួនជាង ៥០ ដែលគ្របដណ្តប់លើកម្មករយ៉ាងហោចណាស់ ១០០.០០០នាក់។ យើងបានប្រើប្រាស់ ទំនាក់ទំនងដ៏ល្អនេះដើម្បីលើកកម្ពស់ការប្រើប្រាស់សេវាសុខភាពរបស់កម្មកររោងចក្រនៅគ្លីនិករ៉ាក់។ សកម្មភាពសំខាន់ៗរបស់យើងនៅតាមរោងចក្រនិមួយៗមានដូចជា៖ ការអប់រំផ្លាស់ប្តូរឥរិយាបថ តាមរយៈមិត្តអប់រំមិត្ត ការអប់រំជាក្រុម ការសម្តែងលើឆាក ពិពណ៌សុខភាព និងការចែកចាយសម្ភារៈអប់រំ។ កម្មវិធីនេះបានលើកកម្ពស់ការប្រើប្រាស់សេវាសុខភាពរបស់កម្មកររោងចក្រនៅគ្លីនិករ៉ាក់តាមរយៈការបង្កើតប្រព័ន្ធបញ្ជូន និងប័ណ្ណសុខភាព។ ក្នុងឆ្នាំ ២០១៥ អង្គការរ៉ាក់អនុវត្តគម្រោងនេះ នៅតាមរោងចក្រចំនួន ៣០ នៅក្នុងរាជធានីភ្នំពេញ ខេត្តព្រះសីហនុ និងខេត្តកំពង់ស្ពឺ។